

# AIA សម្រាប់ឧត្តមសិក្សា

## សន្សំសម្រាប់ការសិក្សាបុត្រធីតាលោកអ្នក
## សន្សំជាមួយនឹងការធានា

សុខភាព និងជីវិត
កាន់តែប្រសើរ



# AIA សម្រាប់ឧត្តមសិក្សា

**ត្រូវបានរចនាឡើងដើម្បីផ្តល់ការធានាលើការសិក្សា ជាមួយកញ្ចប់ហិរញ្ញវត្ថុបម្រុងសម្រាប់ថ្នាក់ឧត្តមសិក្សា ដល់កូនលោកអ្នកប្រកបដោយទំនុកចិត្ត**

ឪពុកម្តាយគ្រប់រូបតែងប្រាថ្នាចង់ឱ្យកូនៗរបស់ពួកគេទទួលបាននូវអ្វីដែលល្អបំផុត ជាមួយអនាគតមួយដែលពោរពេញទៅដោយឱកាស ភាពជោគជ័យ និងមានស្ថិរភាព។ ការអប់រំគឺជាមូលដ្ឋានគ្រឹះដែលអាចនាំទៅរកអនាគតដែលលោកអ្នកប្រាថ្នា ប៉ុន្តែការកើនឡើងនៃចំណាយលើការសិក្សា និងហេតុការណ៍មើលមិនឃើញណាមួយអាចនឹងកើតមានឡើងក្នុងជីវិតរបស់លោកអ្នក ដែលធ្វើឱ្យប៉ះពាល់ដល់គម្រោងរៀបចំការសិក្សាដែលលោកអ្នកបានរំពឹងទុកសម្រាប់កូន។
រៀបចំផែនការទុកជាមុនឥឡូវនេះ ដើម្បីធានាបាននូវអនាគតដ៏ត្រចះត្រចង់សម្រាប់កូនរបស់លោកអ្នក!

## តើ AIA សម្រាប់ឧត្តមសិក្សា ជួយលោកអ្នកក្នុងការធានាលើការសិក្សារបស់បុត្រធីតាលោកអ្នកបានយ៉ាងដូចម្តេច?

**AIA សម្រាប់ឧត្តមសិក្សា** ត្រូវបានរចនាឡើងដើម្បីធានាថាគ្រប់ដំណាក់កាលសំខាន់ៗនៃការសិក្សារបស់កូនលោកអ្នកតែងត្រូវបានធានា។ នេះជាការប្តេជ្ញាចិត្តមួយរបស់លោកអ្នកក្នុងការរៀបចំអនាគតរបស់ពួកគេ ដោយមានកញ្ចប់ហិរញ្ញវត្ថុលើការសិក្សាបម្រុងទុកជានិច្ច ព្រមទាំងមានការការពារផ្នែកហិរញ្ញវត្ថុ ក្នុងករណីមានគ្រោះអកុសលណាមួយកើតឡើងដោយមិននឹកស្មានដល់ចំពោះលោកអ្នក។

គម្រោងនេះផ្តល់នូវលក្ខណៈពិសេសដ៏ទាក់ទាញដូចខាងក្រោម៖

### ប្រាក់សន្សំដែលធានាសម្រាប់ថ្នាក់ឧត្តមសិក្សារបស់បុត្រធីតាលោកអ្នក

រៀបចំអនាគតដ៏ត្រចះត្រចង់លើការសិក្សាសម្រាប់ថ្នាក់ឧត្តមសិក្សាដល់កូនលោកអ្នក ជាមួយទឹកប្រាក់ធានារហូតដល់ **110%*** នៃទឹកប្រាក់បង់បុព្វលាភធានារ៉ាប់រងសរុប សម្រាប់កូនរបស់លោកអ្នកសិក្សានៅសាកលវិទ្យាល័យស្របតាមគោលដៅសន្សំដែលលោកអ្នកប្រាថ្នាចង់បាន។

### ការការពារគ្រប់ជ្រុងជ្រោយដែលអាចពឹងផ្អែកបាននៅពេលសំខាន់បំផុត

ភាពស្ងប់ចិត្តសម្រាប់មាតាបិតាជាមួយការការពារសរុបរហូតដល់ **390%**** នៃចំនួនទឹកប្រាក់ធានារ៉ាប់រងដើមគ្រា។ ប្រសិនបើជីវិតជួបរឿងអកុសល គ្រួសារលោកអ្នកនឹងទទួលប្រាក់សំណងភ្លាមៗដើម្បីជួយសម្រួលដល់តម្រូវការចាំបាច់បន្ទាន់ ទទួលបានប្រាក់ឧបត្ថម្ភប្រចាំឆ្នាំជួយទ្រទ្រង់ជីវភាពគ្រួសារ និងទទួលបានទឹកប្រាក់បន្ថែមលើការសិក្សារបស់កូនលោកអ្នកក្នុងអំឡុងឆ្នាំសិក្សានៅសាកលវិទ្យាល័យរបស់ពួកគេ បន្ថែមពីលើប្រាក់សន្សំលើការសិក្សាដោយមានការធានា។

### អត្ថប្រយោជន៍នៃការបន្តគម្រោងដោយមិនមានការរំខាន

ធានាថឱកាសសម្រាប់ការសិក្សារបស់កូនលោកអ្នកនឹងត្រូវបានផ្តល់ជូនពេញលេញ មិនថាមានអ្វីកើតឡើងចំពោះលោកអ្នកក៏ដោយ។ គម្រោងនេះនឹងនៅតែបន្ត ដោយមិនតម្រូវឱ្យលោកអ្នកបង់បុព្វលាភធានារ៉ាប់រងនាពេលអនាគតនោះទេ។

សម្គាល់៖
*ភាគរយ 110% អាចទទួលបានសម្រាប់តែផលិតផលធានារ៉ាប់រងមូលដ្ឋានប៉ុណ្ណោះ។
**ភាគរយនៃអត្ថប្រយោជន៍ការពារសរុប គឺសម្រាប់អាយុចាប់ពី 4-40ឆ្នាំ ជាមួយរយៈពេលនៃការធានារ៉ាប់រង 18ឆ្នាំ និងរយៈពេលនៃការបង់បុព្វលាភធានារ៉ាប់រង 5ឆ្នាំ ដោយសន្មតថាព្រឹត្តិការណ៍អកុសលកើតឡើងនៅឆ្នាំធានាទី1។

## សេចក្ដីសង្ខេបអត្ថប្រយោជន៍

ធានាកញ្ចប់ការសិក្សារបស់កូនលោកអ្នកនៅតែមានរហូត ជាមួយអត្ថប្រយោជន៍ពិសេសៗជាច្រើន៖

### អត្ថប្រយោជន៍ធានាលើការសិក្សា

ធានាកញ្ចប់ហិរញ្ញវត្ថុជូនកូនរបស់លោកអ្នកជាមួយគោលដៅសន្សំ ដែលលោកអ្នកបានកំណត់ ដើម្បីរៀបចំការសិក្សារបស់ពួកគេនៅសាកលវិទ្យាល័យតាមការប្រាថ្នា ទោះបើមានព្រឹត្តិការណ៍អកុសលណាមួយកើតឡើងក៏ដោយ។ ការបង់សាច់ប្រាក់លើការសិក្សាដែលត្រូវបានធានា នឹងត្រូវផ្ដល់ជូនរយៈពេល 4ឆ្នាំ ស្របទៅតាមការសិក្សារបស់កូនលោកអ្នកនៅសាកលវិទ្យាល័យ។

### អត្ថប្រយោជន៍អបអរសាទរ

ប្រាក់រង្វាន់បន្ថែមផ្ដល់ជូនដើម្បីអបអរភាពជោគជ័យរបស់កូនលោកអ្នក ក្នុងអំឡុងពេលសិក្សានៅសាកលវិទ្យាល័យ។

### អត្ថប្រយោជន៍លើមរណភាព

ផ្ដល់ជូនការទូទាត់សរុបនៃអត្ថប្រយោជន៍លើមរណភាពនៅពេលអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព។ ក្រុមហ៊ុន អេ អាយ អេ នឹងលើកលែងការបង់បុព្វលាភធានារ៉ាប់រងនាពេលអនាគតដើម្បីជួយសម្រាលបន្ទុកផ្នែកហិរញ្ញវត្ថុនៅក្នុងគ្រួសារ ខណៈអត្ថប្រយោជន៍ធានាលើការសិក្សានឹងនៅតែបន្តផ្ដល់ជូន។

### អត្ថប្រយោជន៍លើពិការភាពទាំងស្រុងនិងជាអចិន្ត្រៃយ៍

ផ្ដល់ជូនការទូទាត់សរុបនៃអត្ថប្រយោជន៍លើពិការភាពទាំងស្រុងនិងជាអចិន្ត្រៃយ៍ដោយក្រុមហ៊ុន អេ អាយ អេ ខេមបូឌា នឹងលើកលែងការបង់បុព្វលាភធានារ៉ាប់រងនាពេលអនាគតនៅពេលអ្នកត្រូវបានធានារ៉ាប់រងទទួលរងពិការភាពទាំងស្រុងនិងជាអចិន្ត្រៃយ៍ ខណៈអត្ថប្រយោជន៍ធានាលើការសិក្សា នឹងនៅតែបន្តផ្ដល់ជូន។ បន្ទាប់ពីអត្ថប្រយោជន៍លើពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ត្រូវបានទូទាត់រួចហើយ អត្ថប្រយោជន៍លើមរណភាព នឹងមិនមានទៀតឡើយ។

### អត្ថប្រយោជន៍លើប្រាក់ឧបត្ថម្ភគ្រួសារ

អត្ថប្រយោជន៍បន្ថែមជាប្រាក់ឧបត្ថម្ភប្រចាំឆ្នាំ ជួយសម្រួលបន្ទុកក្នុងគ្រួសាររបស់លោកអ្នក ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ដែលផ្ដល់ជូនរហូតដល់ចុងបញ្ចប់នៃបណ្ណសន្យារ៉ាប់រង។

### អត្ថប្រយោជន៍បន្ថែមលើការសិក្សា

ទឹកប្រាក់ធានារ៉ាប់រងបន្ថែមសម្រាប់សម្រួលផ្នែកហិរញ្ញវត្ថុក្នុងករណីអវត្តមានលោកអ្នក។ ចំនួនទឹកប្រាក់បន្ថែមនេះនឹងត្រូវបង់រួមជាមួយអត្ថប្រយោជន៍ធានាលើការសិក្សា ដើម្បីជួយផ្គត់ផ្គង់បន្ថែមខណៈដែលក្រុមគ្រួសារលោកអ្នកត្រូវការបំផុត។

សម្គាល់៖
1) អត្ថប្រយោជន៍ធានាលើការសិក្សា នឹងត្រូវផ្ដល់ជូននៅកាលបរិច្ឆេទដល់កំណត់ជាដំណាក់កាលរយៈពេល 4 (បួន) ឆ្នាំ។
2) អត្ថប្រយោជន៍អបអរសាទរនឹងត្រូវបានផ្ដល់ជូនក្នុងខណៈដែលអ្នកត្រូវបានធានារ៉ាប់រងនៅរស់រានមានជីវិត រហូតដល់កាលបរិច្ឆេទដល់កំណត់។
3) បន្ទាប់ពីកាលបរិច្ឆេទដល់កំណត់ បណ្ណសន្យារ៉ាប់រងនេះ និងផលិតផលធានារ៉ាប់រងបន្ថែមដែលបានភ្ជាប់ជាមួយបណ្ណសន្យារ៉ាប់នេះ (ប្រសិនបើមាន) ត្រូវបានបញ្ចប់។

## លក្ខខណ្ឌដែលអាចទទួលយកការធានា

- **អ្នកត្រូវបានធានារ៉ាប់រង៖** អាយុ 30ថ្ងៃ – 50ឆ្នាំ
- **ម្ចាស់បណ្ណសន្យារ៉ាប់រង៖** អាយុ 18ឆ្នាំ – 50ឆ្នាំ

## ការទូទាត់បុព្វលាភធានារ៉ាប់រង

- **រយៈពេលនៃការបង់បុព្វលាភធានារ៉ាប់រង៖** 5ឆ្នាំ ឬ 10ឆ្នាំ រហូតដល់ 18ឆ្នាំ
- **របៀបទូទាត់៖** ប្រចាំខែ/ប្រចាំឆមាស/ប្រចាំឆ្នាំ
- **មធ្យោបាយទូទាត់៖** មធ្យោបាយទូទាត់ទាំងអស់ដែលកំណត់ដោយក្រុមហ៊ុន
- **រយៈពេលអនុគ្រោះ៖** 30 (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការទូទាត់បុព្វលាភធានារ៉ាប់រង



លោក វិជ្ជា មានអាយុ **27**ឆ្នាំ ជាមេគ្រួសារ និងមានកូនស្រីម្នាក់ឈ្មោះ វុទ្ធានី អាយុ **8**ខែ។ លោកមានគម្រោងរៀបចំកញ្ចប់ថវិកាបម្រុងនាពេលអនាគតចំនួន **$30,000** សម្រាប់ការសិក្សាកូនស្រីរបស់លោកនៅសាកលវិទ្យាល័យ និងជាពិសេស គឺធានាថាកញ្ចប់ថវិកាសម្រាប់ការសិក្សារបស់កូនស្រីរបស់លោកនៅតែមានរហូត ទោះក្នុងពេលដែលលោកមិននៅក៏ដោយ។ លោកវិជ្ជា សម្រេចចិត្តទិញគម្រោងធានារ៉ាប់រងលើការសិក្សា **“AIA សម្រាប់ឧត្តមសិក្សា”**។

| អ្នកត្រូវបានធានារ៉ាប់រង៖ លោកវិជ្ជា | ទឹកប្រាក់ធានារ៉ាប់រងដើមគ្រា | រយៈពេលនៃការធានារ៉ាប់រង | រយៈពេលនៃការបង់បុព្វលាភធានារ៉ាប់រង | បុព្វលាភធានារ៉ាប់រងប្រចាំឆ្នាំ | បុព្វលាភធានារ៉ាប់រងសរុប |
|---|---|---|---|---|---|
| 27ឆ្នាំ | $30,000 | 18ឆ្នាំ | 18ឆ្នាំ | $1,866.31 | $33,593.58 |

## អត្ថប្រយោជន៍៖

1. **អត្ថប្រយោជន៍ធានាលើការសិក្សា៖ $31,500**
2. **អត្ថប្រយោជន៍បន្ថែមលើការសិក្សា៖ $31,500**
3. **អត្ថប្រយោជន៍អបអរសាទរ៖ $4,401**
4. **អត្ថប្រយោជន៍លើមរណភាព៖ $30,000**
5. **អត្ថប្រយោជន៍លើពិការភាពទាំងស្រុងនិងជាអចិន្ត្រៃយ៍៖ $30,000**
6. **អត្ថប្រយោជន៍លើប្រាក់ឧបត្ថម្ភគ្រួសារ៖ $3,000 ក្នុងមួយឆ្នាំ**

ស្ថានការណ៍ទី1៖ លោក វិជ្ជា រស់នៅដោយសុខសប្បាយរហូតដល់កាលបរិច្ឆេទដល់កំណត់។

អត្ថប្រយោជន៍ធានាលើការសិក្សា
**$31,500**
សម្រាប់បង់ថ្លៃសិក្សារបស់កូនរៀននៅសាកលវិទ្យាល័យ

បូកបង្គរប្រាក់សន្សំបានបង់បុព្វលាភធានារ៉ាប់រង
សរុប **$33,593.58** ក្នុងរយៈពេល **18**ឆ្នាំ

ចុងឆ្នាំនៃបណ្ណសន្យារ៉ាប់រង: 1 ... 18, 19, 20, 21

| ចុងឆ្នាំនៃបណ្ណសន្យារ៉ាប់រង | 18 | 19 | 20 | 21 |
|---|---|---|---|---|
| អត្ថប្រយោជន៍ធានាលើការសិក្សា | $9,000 | $7,500 | $7,500 | $7,500 |
| អត្ថប្រយោជន៍អបអរសាទរ | $1,257 | $1,048 | $1,048 | $1,048 |

**$4,401**
ប្រាក់រង្វាន់បន្ថែមផ្តល់ជូនកូនលោកអ្នកក្នុងអំឡុងពេលសិក្សានៅសាកលវិទ្យាល័យ

**អត្ថប្រយោជន៍សរុបដែលទទួលបាន៖ $35,901**

បន្ទាប់ពីកាលបរិច្ឆេទដល់កំណត់ បណ្ណសន្យារ៉ាប់រងនេះត្រូវបានបញ្ចប់។

**ស្ថានការណ៍ទី2៖** លោក វិជ្ជា បានទទួលមរណភាព ក្នុងឆ្នាំទី5 នៃបណ្ណសន្យារ៉ាប់រង

អត្ថប្រយោជន៍ផ្តល់ជូនទ្វេដង៖ អត្ថប្រយោជន៍ធានាលើការសិក្សា + អត្ថប្រយោជន៍បន្ថែមលើការសិក្សា
**$63,000**
សម្រាប់បង់ថ្លៃសិក្សានិងជួយឧបត្ថម្ភដល់កូនក្នុងពេលគ្មានវត្តមានឪពុក

**អត្ថប្រយោជន៍លើមរណភាព**
**$30,000**

| | | | | |
|---|---|---|---|---|
| | អត្ថប្រយោជន៍ការសិក្សា **$18,000** | អត្ថប្រយោជន៍ការសិក្សា **$15,000** | អត្ថប្រយោជន៍ការសិក្សា **$15,000** | អត្ថប្រយោជន៍ការសិក្សា **$15,000** |
| **ចុងឆ្នាំនៃបណ្ណសន្យារ៉ាប់រង** | 18 | 19 | 20 | 21 |

**ចុងឆ្នាំនៃបណ្ណសន្យារ៉ាប់រង**: 1, 4, 5, 6, 18, 19, 20, 21

លោក វិជ្ជា បានបង់បុព្វលាភធានារ៉ាប់រងសរុប $9,331.55 ក្នុងរយៈពេល 5ឆ្នាំ

គ្រោះអកុសលបានកើតឡើងចំពោះលោក វិជ្ជា ក្នុងឆ្នាំទី5 នៃបណ្ណសន្យារ៉ាប់រង

អត្ថប្រយោជន៍លើប្រាក់ឧបត្ថម្ភគ្រួសារ៖ **$3,000** ត្រូវផ្តល់ជូនជារៀងរាល់ឆ្នាំ ជាប្រាក់ឧបត្ថម្ភបន្ថែមជួយសម្រួលរហូតដល់ចុងបញ្ចប់នៃបណ្ណសន្យារ៉ាប់រង ហើយអត្ថប្រយោជន៍ផ្តល់ជូនសរុបចំនួន៖ **$42,000**

លើកលែងការបង់បុព្វលាភធានារ៉ាប់រង រហូតដល់ចុងគ្រារយៈពេលនៃការធានារ៉ាប់រង

បន្ទាប់ពីកាលបរិច្ឆេទដល់កំណត់ បណ្ណសន្យារ៉ាប់រងនេះត្រូវបានបញ្ចប់។

- ក្រុមគ្រួសារ លោក វិជ្ជា នឹងទទួលបានទឹកប្រាក់ **$30,000** ជាការទូទាត់សរុប ដើម្បីជួយសម្រួលបន្ទុកគ្រួសារក្នុងស្ថានភាពដ៏លំបាកនេះ។
- ក្រុមគ្រួសារ លោក វិជ្ជា នឹងទទួលបានទឹកប្រាក់ **$3,000** ជារៀងរាល់ឆ្នាំ ដើម្បីជួយទ្រទ្រង់ជីវភាពគ្រួសាររហូតដល់ចុងបញ្ចប់នៃបណ្ណសន្យារ៉ាប់រង។
- កូនស្រីរបស់ លោក វិជ្ជា នឹងទទួលបានទឹកប្រាក់ **$63,000** ជាប្រាក់ឧបត្ថម្ភលើការសិក្សានៅសាកលវិទ្យាល័យ។

**អត្ថប្រយោជន៍សរុបដែលទទួលបាន៖ $135,000**

## ការទាមទារសំណង

ប្រសិនបើលោកអ្នកចង់ធ្វើការទាមទារសំណង លោកអ្នកត្រូវបំពេញទម្រង់បែបបទទាមទារសំណង និងផ្តល់ភស្តុតាង ក្នុងអំឡុងពេល 90 ថ្ងៃពីថ្ងៃកើតឡើងនៃព្រឹត្តិការណ៍ដែលត្រូវបានធានារ៉ាប់រង។ លោកអ្នកអាចទាញយកទម្រង់បែបបទទាមទារសំណងពីគេហទំព័ររបស់យើងគឺ aia.com.kh ឬ ពី ទីប្រឹក្សាផែនការជីវិត អេ អាយ អេ។

ភស្តុតាងបញ្ជាក់ពីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ គឺជាឯកសារចាំបាច់ដែលត្រូវតែដាក់ភ្ជាប់ជាមួយនឹងទម្រង់បែបបទទាមទារសំណងមកកាន់ក្រុមហ៊ុន អេ អាយ អេ ខេមបូឌា។ អ្នកទាមទារសំណងអាចស្នើសុំសំណង ប្រសិនបើករណីដែលត្រូវទាមទារសំណងកើតឡើងអំឡុងពេលពេលបណ្ណសន្យារ៉ាប់រងកំពុងមានសុពលភាព។

## ទទួលយកសំណើធានារ៉ាប់រងរបស់លោកអ្នកថ្ងៃនេះ

សូមទាក់ទង **ទីប្រឹក្សាផែនការជីវិត អេ អាយ អេ** ឬ**សេវាបម្រើអតិថិជន អេ អាយ អេ Client Care**

- លេខទូរសព្ទ ៖ 086 999 242
- អ៊ីម៉ែល ៖ KH.Care@aia.com
- គេហទំព័រ ៖ aia.com.kh
- តេឡេក្រាម ៖ AIACambodia bot

## 1. ករណីមិនធានាសម្រាប់អត្ថប្រយោជន៍លើមរណភាព

ក្រុមហ៊ុននឹងមិនធានាលើ មរណភាព ដែលកើតឡើងដោយផ្ទាល់ ឬដោយប្រយោល ពីករណីណាមួយខាងក្រោមនេះឡើយ។ ជំនួសមកវិញ ក្រុមហ៊ុននឹងបង្វិលសងជូនលោកអ្នកវិញនូវបុព្វលាភធានារ៉ាប់រងដែលបានបង់រួច ដោយគ្មានការប្រាក់ ឬបង់ជូនជាតម្លៃសាច់ប្រាក់នៅពេលបោះបង់បណ្ណសន្យារ៉ាប់រងណាមួយដែលច្រើនជាងគេ ដកថ្លៃពិនិត្យសុខភាព (ប្រសិនមាន) ដកបំណុលដែលមាន (ប្រសិនមាន) បន្ទាប់មកបណ្ណសន្យារ៉ាប់រងនេះនឹងត្រូវបញ្ចប់៖

i. ការធ្វើអត្តឃាត ការធ្វើឱ្យរបួសខ្លួនឯង ទោះបីស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតី អំឡុងពេល **2** (ពីរ) ឆ្នាំ ចាប់ពីថ្ងៃចេញបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទដែលចូលជាធរមាន ដោយយកកាលបរិច្ឆេទចុងក្រោយគេ ឬ

ii. ការប្រព្រឹត្ត ឬការប៉ុនប៉ងប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ ដោយម្ចាស់បណ្ណសន្យារ៉ាប់រង ឬដោយអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល ឬ

iii. វីរុសហ៊ីវ និង/ឬជំងឺណាមួយដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ រួមទាំងជំងឺអេដស៍ និង/ឬការផ្លាស់ប្តូរ ការវិវត្ត ឬការប្រែប្រួលនៃ មេរោគអេដស៍ និង/ឬជំងឺដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ រួមទាំងជំងឺអេដស៍ ឬ

iv. ការប្រើប្រាស់គ្រឿងញៀន ឬថ្នាំសប្បាយ ការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ដូចមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដូចជា ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ល។

## 2. ករណីមិនធានាសម្រាប់អត្ថប្រយោជន៍លើពិការភាពទាំងស្រុងនិងជាអចិន្ត្រៃយ៍

ក្រុមហ៊ុននឹងមិនធានាលើពិការភាពទាំងស្រុងនិងជាអចិន្ត្រៃយ៍ ដែលកើតឡើងដោយផ្ទាល់ ឬដោយប្រយោល ទាំងស្រុង ឬដោយផ្នែកណាមួយ ពីករណីណាមួយខាងក្រោមនេះឡើយ។ ជំនួសមកវិញ ក្រុមហ៊ុននឹងបង្វិលសងជូនអ្នកវិញនូវបុព្វលាភធានារ៉ាប់រងដែលបានបង់រួចដោយគ្មានការប្រាក់ ឬបង់ជូនជាតម្លៃសាច់ប្រាក់នៅពេលបោះបង់បណ្ណសន្យារ៉ាប់រងមួយណាដែលច្រើនជាងគេ ដកថ្លៃពិនិត្យសុខភាព (ប្រសិនបើមាន) ដកបំណុលដែលមាន (ប្រសិនបើមាន) បន្ទាប់មកបណ្ណសន្យារ៉ាប់រងនេះនឹងត្រូវបញ្ចប់៖

i. ការប្រឈមនឹងគ្រោះថ្នាក់ដោយចេតនា ឬប៉ុនប៉ងធ្វើបាបខ្លួនឯងដោយចេតនា ឬធ្វើឱ្យរបួសខ្លួនឯងទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ ឬ

ii. ការចូលបម្រើក្នុងជួរកងទ័ព ក្នុងអំឡុងពេលមានប្រកាស ឬគ្មានប្រកាសសង្គ្រាមក្តី ឬក្រោមបញ្ជាប្រតិបត្តិការសង្គ្រាម ឬការស្តារសណ្តាប់ធ្នាប់សាធារណៈ ឬ

iii. ការធ្វើដំណើរចូល ការចាកចេញ ការធ្វើប្រតិបត្តិការ ការផ្តល់សេវា ឬត្រូវបានបញ្ជូនដោយយាន ឬមធ្យោបាយធ្វើដំណើរតាមផ្លូវអាកាស លើកលែងតែក្នុងករណីសមាជិកអ្នកត្រូវបានធានារ៉ាប់រងគឺជាអ្នកដំណើរធម្មតា ឬសមាជិកអ្នកបម្រើលើយន្តហោះនៃក្រុមហ៊ុនអាកាសចរណ៍ណាមួយដែលធ្វើការជាប្រចាំតាមកាលវិភាគនៃអ្នកធ្វើដំណើររបស់ក្រុមហ៊ុនអាកាសចរណ៍ និងតាមគន្លងផ្លូវអាកាសសម្រាប់អ្នកធ្វើដំណើរតាមផ្លូវអាកាស ឬ

iv. ពិការភាពទាំងស្រុងនិងជាអចិន្ត្រៃយ៍ ដែលបណ្តាលមកពីបញ្ហាផ្លូវកាយ ឬផ្លូវចិត្ត ដែលកើតមានមុនកាលបរិច្ឆេទសុពលភាពនៃការធានារ៉ាប់រងរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រង ហើយដែលមិនបានបង្ហាញក្នុងពាក្យស្នើសុំ ឬរបាយការណ៍សុខភាព ឬ

v. ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ប្រព្រឹត្ត ឬប៉ុនប៉ងនឹងប្រព្រឹត្ត ដោយម្ចាស់បណ្ណសន្យារ៉ាប់រង ឬដោយសមាជិកអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល ឬ

vi. ការប្រើប្រាស់គ្រឿងញៀន ឬថ្នាំសប្បាយ ការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ដូចមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដូចជា ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ល។

## ករណីមិនធានា

### 3. ករណីមិនធានាពាក់ព័ន្ធនឹងទណ្ឌកម្មអន្តរជាតិ

i. ក្រុមហ៊ុនអាចលុបចោលបណ្ណសន្យារ៉ាប់រងនេះនៅពេលណាមួយក៏បាន (ដោយការលុបចោលសុពលភាពគិតចាប់ពីកាលបរិច្ឆេទចេញបណ្ណសន្យារ៉ាប់រង ឬផ្សេងពីនេះ) តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់បណ្ណសន្យារ៉ាប់រង ក្នុងករណីដែលម្ចាស់បណ្ណសន្យារ៉ាប់រង ឬបុគ្គល ឬអង្គភាពណាមួយដែលពាក់ព័ន្ធនៅក្នុងបណ្ណសន្យារ៉ាប់រងនេះ តាមការយល់ឃើញរបស់ក្រុមហ៊ុន ត្រូវបានរកឃើញថាបានបង្ក ឬអាចនឹងបង្កហានិភ័យផ្នែកទណ្ឌកម្ម ការហាមប្រាម ឬការរឹតបន្តឹងមកដល់ក្រុមហ៊ុនតាមរយៈសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ឬការដាក់ទណ្ឌកម្មផ្នែកសេដ្ឋកិច្ច/ពាណិជ្ជកម្ម លិខិតបទដ្ឋានគតិយុត្តិរបស់សហភាពអឺរ៉ុប ចក្រភពអង់គ្លេស ឬសហរដ្ឋអាមេរិក ឬតាមការអនុវត្តច្បាប់ ឬបទបញ្ញត្តិផ្សេងៗស្តីពីការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ឬពាណិជ្ជកម្ម។ ក្រុមហ៊ុននឹងមិនធ្វើប្រតិបត្តិការអាជីវកម្មជាមួយម្ចាស់បណ្ណសន្យារ៉ាប់រងពាក់ព័ន្ធនឹងបណ្ណសន្យារ៉ាប់រងនេះនោះទេ ដោយរួមបញ្ចូលទាំង និងមិនកំណត់ត្រឹមតែការផ្តល់ ឬទទួលទូទាត់ទឹកប្រាក់ក្រោមបណ្ណសន្យារ៉ាប់រងនេះ។ ក្រុមហ៊ុនសូមរក្សាសិទ្ធក្នុងការចាត់វិធានការផ្សេងទៀតដែលគិតថាសមហេតុផល ដោយរួមបញ្ចូលទាំង និងមិនកំណត់ចំពោះការជូនដំណឹងដល់អាជ្ញាធរដែលពាក់ព័ន្ធ ការរក្សាទុកការទូទាត់ប្រាក់សំណង ឬអត្ថប្រយោជន៍ផ្សេងទៀត ឬបង្កកទឹកប្រាក់បុព្វលាភដែលបានបង់រួច និងផ្ទេរការទូទាត់ ឬទឹកប្រាក់ទៅកាន់អាជ្ញាធរដែលពាក់ព័ន្ធណាមួយ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ii. ដោយមិនមានការប៉ះពាល់ដល់សុពលភាពកថាខណ្ឌ (i) ខាងលើនៃប្រការនេះទេ បណ្ណសន្យារ៉ាប់រងនេះនឹងត្រូវចាត់ទុកថាមិនត្រូវផ្តល់ការធានាណាមួយឡើយ ហើយក្រុមហ៊ុនក៏មិនទទួលខុសត្រូវក្នុងការទូទាត់សំណង ឬផ្តល់អត្ថប្រយោជន៍ផ្សេងៗក្នុងទំហំដែលការផ្តល់ការការពារ ការទូទាត់សំណង ឬការផ្តល់ជូននូវអត្ថប្រយោជន៍ផ្សេងៗទាំងនោះ អាចនាំឲ្យក្រុមហ៊ុនប្រឈមមុខនឹងហានិភ័យនានាពាក់ព័ន្ធនឹងការដាក់ទណ្ឌកម្ម ការហាមប្រាម ឬការរឹតបន្តឹងក្រោមសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ឬការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ឬពាណិជ្ជកម្ម លិខិតបទដ្ឋានគតិយុត្តិរបស់សហភាពអឺរ៉ុប ឬចក្រភពអង់គ្លេស ឬសហរដ្ឋអាមេរិក ឬការអនុវត្តច្បាប់ ឬបទបញ្ញត្តិផ្សេងៗស្តីពីការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ឬពាណិជ្ជកម្ម។

iii. ជាកាតព្វកិច្ចដែលត្រូវអនុវត្តបន្តជាប្រចាំ ម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវជូនដំណឹងជាបន្ទាន់ទៅកាន់ក្រុមហ៊ុន ប្រសិនបើមានករណីផ្លាស់ប្តូរអត្តសញ្ញាណ ស្ថានភាព (មុខដំណែង) លក្ខន្តិកៈ (ក្នុងករណីជាក្រុមហ៊ុន) ក្រុមហ៊ុនពាក់ព័ន្ធនឹងម្ចាស់បណ្ណសន្យារ៉ាប់រងក្រោមខ្លឹមសារនៃបណ្ណសន្យារ៉ាប់រងនេះ ព័ត៌មានលម្អិត និងឯកសារអត្តសញ្ញាណកម្មរបស់ម្ចាស់បណ្ណសន្យារ៉ាប់រង ឬបុគ្គល ឬអង្គភាពនានាដែលពាក់ព័ន្ធនឹងបណ្ណសន្យារ៉ាប់រងនេះ។

## ជម្រើសផលិតផលធានារ៉ាប់រងបន្ថែម

**បន្ថែមការការពាររបស់លោកអ្នកជាមួយជម្រើសផលិតផលធានារ៉ាប់រងបន្ថែម៖**

### 1. ផលិតផលធានារ៉ាប់រងបន្ថែមលើប្រាក់ឧបត្ថម្ភគ្រួសារ

ការការពារបន្ថែមដើម្បីធានាថាកូនរបស់លោកអ្នក ឬគ្រួសាររបស់លោកអ្នក នឹងទទួលបានប្រាក់ឧបត្ថម្ភបន្ថែមប្រចាំឆ្នាំ ប្រសិនបើមានព្រឹត្តិការណ៍អកុសលណាមួយកើតឡើង។

### 2. ផលិតផលធានារ៉ាប់រងបន្ថែមលើមរណភាព ពិការភាព និងការរលាកដោយគ្រោះថ្នាក់ចៃដន្យ

បង្កើនកម្រិតការពាររបស់លោកអ្នកនិងមនុស្សជាទីស្រលាញ់របស់លោកអ្នកនឹងទទួលបានការការពារផ្នែកហិរញ្ញវត្ថុប្រសិនបើមានព្រឹត្តិការណ៍អកុសលណាមួយកើតឡើងដោយគ្រោះថ្នាក់ចៃដន្យ។

### 3. ផលិតផលធានារ៉ាប់រងបន្ថែមលើចំណាយសម្រាកព្យាបាលក្នុងមន្ទីរពេទ្យដោយសារគ្រោះថ្នាក់ចៃដន្យ

ផ្តល់ជូនលោកអ្នកនូវទឹកប្រាក់សំណងជាប្រចាំថ្ងៃ ដើម្បីជំនួសការបាត់បង់ប្រាក់ចំណូលរបស់លោកអ្នក ក្នុងករណីតម្រូវឱ្យមានការចូលសម្រាកក្នុងមន្ទីរពេទ្យដែលបង្កឡើងពីគ្រោះថ្នាក់ចៃដន្យ។

### 4. AIA 100 ការពារ PRO

ផ្តល់ការការពារលើជំងឺធ្ងន់ធ្ងររហូតដល់ **118** ករណី ចាប់តាំងពីដំណាក់កាលដំបូង រហូតដល់ដំណាក់កាលចុងក្រោយ បន្ថែមទាំងការការពារលើជំងឺ និងករណីបណ្តាលមកពីផលវិបាកនៃជំងឺទឹកនោមផ្អែម។ លោកអ្នកនឹងទទួលបានទឹកប្រាក់សំណងនៃអត្ថប្រយោជន៍លើជំងឺធ្ងន់ធ្ងរ ដែលអាចជួយសម្រាលការចំណាយលើការព្យាបាលជំងឺនៅមន្ទីរពេទ្យ និងផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុបានទាន់ពេលវេលាក្នុងកាលៈទេសៈដែលលោកអ្នកត្រូវការបំផុត ហើយលោកអ្នកអាចផ្តោតការយកចិត្តទុកដាក់តែលើការព្យាបាលជំងឺនេះឱ្យបានជាសះស្បើយ។

## 5. AIA ការពារ PREMIUM

លើកលែងការបង់បុព្វលាភធានារ៉ាប់រងនាពេលអនាគតប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងធ្វើរោគវិនិច្ឆ័យឃើញថាមានជំងឺធ្ងន់ធ្ងរដំណាក់កាលដំបូង ឬដំណាក់កាលចុងក្រោយ ដូចដែលបានកំណត់ក្រោមផលិតផលធានារ៉ាប់រងបន្ថែមនេះ ក្នុងអំឡុងពេលនៃការធានារ៉ាប់រង។

## 6. AIA ការពារ PREMIUM[PAYOR]

លើកលែងការបង់បុព្វលាភធានារ៉ាប់រងនាពេលអនាគតប្រសិនបើម្ចាស់បណ្ណធ្វើរោគវិនិច្ឆ័យឃើញថាមានជំងឺធ្ងន់ធ្ងរដំណាក់កាលដំបូង ឬដំណាក់កាលចុងក្រោយ ឬទទួលមរណភាព ឬទទួលរងពិការភាពទាំងស្រុងនិងជាអចិន្ត្រៃយ៍ ដូចដែលបានកំណត់ក្រោមផលិតផលធានារ៉ាប់រងបន្ថែមនេះ ក្នុងអំឡុងពេលនៃការធានារ៉ាប់រង។

## 7. ផលិតផលធានារ៉ាប់រងបន្ថែមលើអត្ថប្រយោជន៍ប្រាក់ឧបត្ថម្ភសម្រាកក្នុងមន្ទីរពេទ្យ

ផ្តល់ប្រាក់ឧបត្ថម្ភជាសាច់ប្រាក់ក្នុងការចំណាយប្រចាំថ្ងៃលើការសម្រាកនៅក្នុងមន្ទីរពេទ្យ ថែមទាំងការផ្តល់ជូនក្នុងករណីសម្រាកព្យាបាលក្នុងបន្ទប់សង្គ្រោះបន្ទាន់ (ICU) ដែលបង្កដោយគ្រោះថ្នាក់ចៃដន្យ ឬជំងឺណាមួយ។

## 8. ផលិតផលធានារ៉ាប់រងបន្ថែមលើអត្ថប្រយោជន៍ការពារគ្រោះថ្នាក់ចៃដន្យសម្រាប់កូន

គម្រោងធានារ៉ាប់រងបុគ្គលដែលផ្តល់ការការពារលើគ្រោះថ្នាក់ចៃដន្យសម្រាប់កុមារ ក្នុងករណីគ្រោះថ្នាក់ចៃដន្យបណ្តាលឱ្យទទួលមរណភាព ពិការភាព និងការរលាក លើកុមារដែលមានអាយុចាប់ពី **30**ថ្ងៃ ឡើងទៅ។

**ការិយាល័យកណ្ដាល**
អគារ ជីអាយអេ ថៅអឺរ ជាន់ទី**31** ផ្លូវសុភមង្គល ភូមិ**14** សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ

**សាខាសៀមរាប**
អគារលេខ **29**និង**30**
ផ្លូវហ្សាលដឺហ្គោល សាលាកន្សែង សង្កាត់ស្វាយដង្គំ ទីរួមខេត្តសៀមរាប

**សាខាបាត់ដំបង**
ផ្ទះលេខ**2-6** ផ្លូវលេខ**3** ភូមិកម្មករ សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង
ខេត្តបាត់ដំបង

**សាខាកំពង់ចាម**
ភូមិ**15** សង្កាត់កំពង់ចាម ខណ្ឌកំពង់ចាម ខេត្តកំពង់ចាម

**សាខាកំពត**
ផ្លូវលេខ**700** ភូមិ**1**ឧសភា សង្កាត់កំពង់កណ្ដាល ក្រុងកំពត ខេត្តកំពត

086 999 242 | AIA.COM.KH | AIA CAMBODIA